ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈឆ្មបកម្ពុជា

# កូនសៀវភៅឆ្មប

ឆ្នាំ២០១៣

# មាតិកា


| | |
|---|---|
| អារម្ភកថា | ២ |
| និយមន័យឆ្នប | ៤ |
| ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឆ្នបកម្ពុជា | ៥ |
| អនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្នប | ១៦ |
| សំនួរជាញឹកញាប់អំពីគណៈឆ្នបកម្ពុជា | ២៥ |
| អំពីគណៈឆ្នបកម្ពុជា | ២៨ |
| ដំណើរការនៃពាក្យបណ្តឹង ការស៊ើបអង្កេត និងសវនាការរបស់ក្រុមប្រឹក្សាគណៈឆ្នបភូមិភាគ និងជាតិ | ៣០ |
| រចនាសម្ព័ន្ធរបស់គណៈឆ្នបកម្ពុជា | ៣១ |
| បញ្ជីឯកសារពាក់ព័ន្ធ | ៣៣ |
| ព័ត៌មានបន្ថែម | ៣៣ |

# អារម្ភកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងការបង្ហាញនូវកូនសៀវភៅឆ្មប នេះជាលើកដំបូងសម្រាប់ឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា ។ តាមរយៈការចុះបញ្ជីរបស់ឆ្មបទាំងអស់ គណៈឆ្មបកម្ពុជាប្តេជ្ញាចិត្តធានាឲ្យបាននូវស្តង់ដារវិជ្ជាជីវៈខ្ពស់ ដើម្បីការពារសាធារណជន និងកាត់បន្ថយអត្រាមរណភាពមាតា និងទារក។

កូនសៀវភៅនេះពិពណ៌នាពីក្រមសីលធម៌ឆ្មប ព័ត៌មានពីគណៈឆ្មបកម្ពុជា និងឯកសារយោងផ្សេងៗទៀត។គណៈឆ្មបកម្ពុជាទទួលស្គាល់ថា បច្ចុប្បន្នឆ្មបត្រូវការពេលវេលាមួយសមស្របដើម្បីទទួលបាននូវការបណ្តុះបណ្តាល និងបទពិសោធន៍បន្ថែមទៀត។ នាពេលអនាគតគណៈឆ្មបកម្ពុជា មានតួនាទីរៀបចំស្តង់ដារសម្រាប់ការអប់រំមូលដ្ឋាននិងបន្តដល់ឆ្មប ដោយផ្អែកលើស្តង់ដារជាសាកលរបស់សហព័ន្ធឆ្មបអន្តរជាតិ ( ICM ) ដែលនឹងឈានទៅដល់ការលើកកម្ពស់សមត្ថភាពឆ្មប។ កូនសៀវភៅឆ្មបនេះមានសារសំខាន់សម្រាប់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ដែលអនុវត្តការងារយ៉ាងជិតស្និទ្ធជាមួយឆ្មប ហើយត្រូវការស្វែងយល់ពីតួនាទី និងក្រមសីលធម៌របស់ឆ្មប និងមានសារៈសំខាន់ផងដែរសម្រាប់សាធារណជនជាពិសេសគឺស្ត្រីដើម្បីឲ្យពួកគេអាចដឹងពីការអនុវត្តន៍ក្រមសីលធម៌ឆ្មប ។

ឆ្លៀតក្នុងឱកាសនេះ តាងនាមឲ្យសមាជិកទាំងអស់នៃគណៈឆ្មបកម្ពុជា និងក្នុងនាមក្រុមប្រឹក្សាគណៈឆ្មបជាតិ នាងខ្ញុំសូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែបានយកចិត្តទុកដាក់ជួយឧបត្ថម្ភនិងលើកទឹកចិត្តដល់ឆ្មប និងសូមថ្លែងអំណរគុណចំពោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាលដែលបានជួយឧបត្ថម្ភ និងគាំទ្រគ្រប់បែបយ៉ាងដល់ដំណើរការរបស់គណៈឆ្មបកម្ពុជា ព្រមទាំងអរគុណចំពោះមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ( UNFPA ) ដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ពកូនសៀវភៅឆ្មបនេះ ។

គណៈឆ្មបកម្ពុជាសង្ឃឹមនិងជឿជាក់ថា   តាមរយៈកូនសៀវភៅនេះឆ្មបទាំងអស់ នឹងអនុវត្តន៍ការងាររបស់ខ្លួនដោយមានការទទួលខុសត្រូវ ភាពសុចរិត អភិវឌ្ឍន៍ និងធ្វើបច្ចុប្បន្នភាពសមត្ថភាពក្នុងការអនុវត្តន៍វិជ្ជាជីវៈឆ្មបរបស់ខ្លួន ឲ្យមានកម្រិតខ្ពស់ ។

រាជធានីភ្នំពេញ , ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១៣

ជ. ក្រុមប្រឹក្សាគណៈឆ្មបជាតិ

ប្រធាន

CAMBODIAN MIDWIVES COUNCIL

អ៊ីច រ៉ាដា

## និយមន័យឆ្មប

ឆ្មបគឺជាបុគ្គលដែលបញ្ចប់ការសិក្សាកម្មវិធីឆ្មបដោយផ្អែកលើក្របខណ្ឌសមត្ថភាពស្នូលសម្រាប់ឆ្មបវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយជោគជ័យនិងទទួលស្គាល់ក្នុងប្រទេស បំពេញតាមគុណវុឌ្ឍិក្នុងការចុះបញ្ជី មានអាជ្ញាប័ណ្ណស្រមច្បាប់ ដើម្បីប្រកបវិជ្ជាជីវៈឆ្មប ប្រើប្រាស់តួនាទីឆ្មប និងបញ្ជាក់ថាខ្លួនមានសមត្ថភាពជំនាញក្នុងការអនុវត្តវិជ្ជាជីវៈឆ្មប។

១. ឆ្មបបឋមជាបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យទទួលបាននូវកម្មវិធីអប់រំផ្នែកឆ្មបទៀងទាត់ និងបានបញ្ចប់ដោយជោគជ័យនូវវគ្គសិក្សាដែលកំណត់ដោយច្បាប់ យ៉ាងហោចណាស់រយៈពេលមួយឆ្នាំខាងផ្នែកឆ្មប ហើយទទួលបាននូវគុណវុឌ្ឍិចាំបាច់ដើម្បីបានចុះបញ្ជីក្នុងការទទួលបាននូវសិទ្ធិអនុវត្តការងារឆ្មប ជាឆ្មបបឋម។

២. ឆ្មបមធ្យមជាបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យទទួលបាននូវកម្មវិធីអប់រំផ្នែកឆ្មបទៀងទាត់ និងបានបញ្ចប់ដោយជោគជ័យនូវវគ្គសិក្សាដែលកំណត់ដោយច្បាប់ យ៉ាងហោចណាស់រយៈពេល៣ឆ្នាំខាងផ្នែកឆ្មប ឬនិស្សិតដែលបញ្ចប់វគ្គសិក្សាផ្នែកគិលានុបដ្ឋាក -យិកា ដោយបានទទួលការបណ្ដុះបណ្ដាលផ្នែកឆ្មបមួយឆ្នាំបន្ថែមទៀត ហើយបានទទួលនូវគុណវុឌ្ឍិចាំបាច់ដើម្បីចុះបញ្ជីក្នុងការទទួលបានសិទ្ធិអនុវត្តការងារឆ្មប។

៣. ឆ្មបបរិញ្ញាប័ត្រជាបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យទទួលបាននូវកម្មវិធីអប់រំផ្នែកឆ្មបទៀងទាត់យ៉ាងហោចណាស់រយៈពេល៤ឆ្នាំនិង បានបញ្ចប់ដោយជោគជ័យនូវវគ្គសិក្សា កម្រិតបរិញ្ញាប័ត្រផ្នែកឆ្មបដែលកំណត់ដោយច្បាប់ ហើយបានទទួលគុណវុឌ្ឍិចាំបាច់ដើម្បីបានចុះបញ្ជីក្នុងការទទួលបាននូវសិទ្ធិអនុវត្តការងារឆ្មប។

# ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឆ្មបកម្ពុជា

នស/រកត/០៩០៦/៣៥៩

## ព្រះរាជក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈឆ្មបកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៧៩/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដោយបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

**ត្រាស់បង្គាប់**

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈឆ្មបមួយ ដើម្បីប្រមូលផ្តុំឆ្មបទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ និង អមវេជ្ជសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថាឆ្មបក្នុងព្រះរាជក្រឹត្យនេះគឺ នីតិជនដែលមានសញ្ញាប័ត្រឆ្មបចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាប័ត្រឆ្មបចេញដោយគ្រឹះស្ថានសិក្សាដែលបានទទួលស្គាល់គុណភាពអប់រំដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ឆ្មបទាំងអស់ដែលប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប។

ចំពោះឆ្មបបុរាណក្រសួងសុខាភិបាលមានគោលនយោបាយដោយឡែក ។

## ជំពូកទី២
## បេសកកម្មរបស់គណៈឆ្មប

**មាត្រា ២.-**

គណៈឆ្មប ត្រូវឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍សីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈឆ្មប ត្រូវឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ឆ្មប ។

គណៈឆ្មប ធានាការពារកិត្តិយស និង ឥស្សរភាពរបស់វិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ។

គណៈឆ្មប បំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈឆ្មប ខេត្ត ក្រុង ដែលសរសេរកាត់ថា **ក.ឆ.ខ.** ក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ ដែលសរសេរកាត់ថា **ក.ឆ.ភ.** និង ក្រុមប្រឹក្សាគណៈឆ្មបជាតិ ដែលសរសេរ កាត់ថា **ក.ឆ.ជ.** ។

## ផ្នែកទី ១
## តួនាទីសីលធម៌

**មាត្រា ៣.-**

គណៈឆ្មបមានបន្ទុករៀបរៀងក្រមសីលធម៌ឆ្មប យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈក្នុងការវិវត្តន៍ខ្ជាប់ខ្ជួនខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ចដែលត្រូវធ្វើឱ្យវិវត្តន៍ល្អក្នុងផលប្រយោជន៍របស់អ្នកជំងឺ ។

គណៈឆ្មបតាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ សេចក្តីគោរពប្រណិប័ត្តិ ។

គណៈឆ្មបជាអង្គការស្វយ័ត ។ ការចំណាយ ការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាពការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី ២

## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា ៤.-**

ការចាត់ចែងអំណាចត្រូវអនុលោមតាមបញ្ជាគណៈឆ្មប ។

គណៈឆ្មបត្រូវរៀបចំធ្វើ និង ថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមឆ្មប ដែលបានចុះឈ្មោះបំពេញលក្ខខណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

ភាតព្វកិច្ចនៃការចុះឈ្មោះ ក្នុងបញ្ជីរាយនាមឆ្មប គឺដើម្បីបំពេញការរៀបចំថែទាំព្យាបាលជំងឺ ។

គណៈឆ្មបជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនេះ ។

## ផ្នែកទី ៣

## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា ៥.-**

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ឆ្មបណាមួយទៅគណៈឆ្មប មិនមែនជាឧបសគ្គក្នុងការធ្វើបណ្តឹងចំពោះការប្រព្រឹត្តខុសឆ្គងនេះ ទៅតុលាការឡើយ ។

## ផ្នែកទី ៤

## តួនាទីពិភាក្សាផ្តល់យោបល់

**មាត្រា ៦.-**

គណៈឆ្មបអាចត្រូវបានកោះហៅឱ្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឆ្មបទាំងឡាយ ។

## ផ្នែកទី៥

## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា ៧.-**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យដល់ឆ្មប និងគ្រួសាររបស់គេ ។ ការជួយសង្គ្រោះគ្នាបានរៀបចំតាមបែបបទដូចតទៅ ÷

- គណៈឆ្មបត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បម្រុងសម្រាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាម១ ក្នុងករណីសមរម្យដល់គ្រួសារឆ្មប ដែលត្រូវរងទុក្ខលំបាក
- គណៈឆ្មបត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមឆ្មបកម្ពុជាម្នាក់ជាសមាជិក
- គណៈកម្មការនេះ ចាត់ចែងឱ្យមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីឆ្មប

ម្នាក់ៗដែលចុះឈ្មោះ ក្នុងគណៈឆ្មប ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ
## ផ្នែកទី១
## ក្រុមប្រឹក្សាគណៈឆ្មបថ្នាក់ខេត្ត ក្រុង (ក.ឆ.ខ.)

**មាត្រា ៨.-**

ក.ឆ.ខ. ត្រូវបង្កើតនៅតាមខេត្ត ក្រុងនីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត ក្រុង ដែលមានចំនួនឆ្មបតិចជាងម្ភៃ (២០)នាក់ ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេដើម្បីបង្កើតក្រុមប្រឹក្សាគណៈឆ្មប ។

**មាត្រា ៩.-**

ក.ឆ.ខ. ត្រូវមានសមាជិកពេញសិទ្ធិចំនួនប្រាំបួន (០៩)រូប និងសមាជិកជំនួសចំនួនប្រាំបួន(០៩)រូប ក្នុងករណីដែលចំនួនឆ្មបដែលបានចុះឈ្មោះក្នុងបញ្ជីមានមិនលើសពីមួយរយ (១០០) នាក់ ។ ចំនួននេះនឹងឡើងទៅដល់ដប់មួយ (១១), ដប់ប្រាំ (១៥), ដប់ប្រាំបួន(១៩) ឬ ម្ភៃមួយ (២១)រូប បើសិនចំនួនឆ្មបនៅក្នុងបញ្ជីមានលើសពីមួយរយ(១០០), ប្រាំរយ(៥០០), មួយពាន់ (១.០០០) ឬ ពីរពាន់ (២.០០០) នាក់ ។

**មាត្រា ១០.-**

ក.ឆ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយបណ្តាឆ្មបដែលបានចុះឈ្មោះ នៅក្នុងបញ្ជីរបស់ ក.ឆ.ខ. សម្រាប់រយៈពេលប្រាំមួយ (០៦)ឆ្នាំ ។

សមាជិកចប់អាណត្តិ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សា ធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេលពីរ (០២)ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ក្នុងករណីដែលចំនួនសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

សមាសភាពការិយាល័យរបស់ក.ឆ.ខ. រួមមាន ប្រធានក្រុមប្រឹក្សាមួយរូបអនុប្រធានមួយ (០១) រូបអគ្គលេខាធិការ មួយ (០១ )រូប ហិរញ្ញិកមួយ (០១ )រូប និងសមាជិកប្រាំ (០៥ )រូប ។

**មាត្រា ១១.-**

ក.ឆ.ខ. បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត ក្រុងរបស់ខ្លួន និង ក្រោមការត្រួតពិនិត្យរបស់គណៈឆ្មបជាតិ ចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ។ ក.ឆ.ខ. សម្រេចអារកាត់ក្នុងការចុះឈ្មោះឆ្មបដែលបានបំពេញល័ក្ខខ័ណ្ឌតាម មាត្រា៣ ជំពូកទី១ និង មាត្រា៦ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ នៅក្នុង

បញ្ជីរបស់គណៈឆ្មប ។ គ.ឆ.ខ. មិនប្រកាន់ភេទ ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬ ស្ថានភាព ឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា ១២.-**

គ.ឆ.ខ. ពុំមានអំណាចដាក់វិន័យទេ បើមានពាក្យប្តឹងចំពោះឆ្មបដែលស្ថិតក្រោម សមត្ថកិច្ច របស់ខ្លួន គ.ឆ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា ១៣.-**

ប្រធានតំណាងឱ្យ គ.ឆ.ខ. នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

**មាត្រា ១៤.-**

ការប្រជុំនៃក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ ។ កាលណាមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានខាងឧត្តមានុភាពសម្រេច ។ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសម្លេងពិគ្រោះយោបល់ ។ គ.ឆ.ខ. អាចអញ្ជើញទីប្រឹក្សាច្បាប់មួយរូបចូលរួមក្នុងអង្គប្រជុំ ។

**មាត្រា ១៥.-**

ឆ្មបនៅតាមបណ្តាខេត្ត ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជី ដែលកាន់កាប់ជាប្រចាំដោយក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុងពាក់ព័ន្ធ ។ អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប តែចំពោះឆ្មបដែលមានសញ្ញាប័ត្រឆ្មប ចេញដោយក្រសួងសុខាភិបាល ឬសញ្ញាប័ត្រចេញដោយគ្រឹះស្ថានសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង បានបំពេញល័ក្ខខ័ណ្ឌច្បាប់ និង ក្រមសីលធម៌ដែលបានកំណត់ ។

ឆ្មបអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃខេត្ត ក្រុងដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៦.-**

គ.ឆ.ខ. ត្រូវសម្រេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរបី(០៣)ខែ ដោយគិតចាប់តាំងពីថ្ងៃទទួលពាក្យដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅឆ្មបសាមី ។ បើមានការបដិសេធលើសំណើរសុំចុះឈ្មោះ គ.ឆ.ខ. ត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ។

ការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបខេត្ត ក្រុងនីមួយៗ ត្រូវជូនដំណឹងយ៉ាងយូរពីរសប្តាហ៍ទៅអាជ្ញាធរ ខេត្ត ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត ក្រុងពាក់ព័ន្ធ និង ទៅក្រុមប្រឹក្សាគណៈឆ្មបជាតិ ។

**មាត្រា ១៧.-**

ក្រោយពីបានអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបខេត្ត ក្រុង ដែលខ្លួនកំពុងប្រកបវិជ្ជាជីវៈ

ឆ្មបអាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនៅខេត្ត ក្រុងដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត ក្រុង ដែលខ្លួនបានសុំចុះឈ្មោះ ឆ្មបត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសារជាថ្មី ទៅក្រុមប្រឹក្សាខេត្ត ក្រុងដែលខ្លួនទៅរស់នៅប្រកបវិជ្ជាជីវៈ ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុង ត្រូវទទួលបណ្តឹងជំទាស់ពីក្រុមប្រឹក្សាជាតិ សមាគមឆ្មប រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការ ឬឆ្មបណាម្នាក់ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប រួចហើយធ្វើរបាយការណ៍ផ្ញើជូនគណៈឆ្មបជាតិ ។

## ផ្នែកទី២

## ក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ (ក.ឆ.ភ.)

**មាត្រា ១៩.-**

ការបែងចែកភូមិភាគសម្រាប់គណៈឆ្មបកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ៖

ភូមិភាគ ១ : រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។

ភូមិភាគ ២ : មានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។

ភូមិភាគ ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត ។

ភូមិភាគ ៤ : មានខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។

ភូមិភាគ ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

**មាត្រា ២០.-**

ក.ឆ.ភ. មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម មានសមាជិកពេញសិទ្ធិ ចំនួនប្រាំបួន (០៩)រូប និង សមាជិកជំនួសចំនួនប្រាំបួន (០៩) រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម ក.ឆ.ខ. ក្នុងភូមិភាគ។ ក.ឆ.ខ. នីមួយៗ ត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិចមួយ (០១) រូបពេញសិទ្ធិ និងមួយ (០១) រូបជាជំនួស ចំនួនអាសនៈដែលនៅសល់ ត្រូវបែងចែកទៅខេត្ត ក្រុង ដោយផ្អែកទៅលើចំនួនឆ្មប ដែលបានចុះឈ្មោះជាសមាជិកក្រុមប្រឹក្សាភូមិភាគ ។សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល ០៦ឆ្នាំ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សា

ធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងសមាសភាពនៃការិយាល័យ នៅក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួសត្រូវចូលជំនួយសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

ការិយាល័យមានសមាសភាព : ប្រធានមួយ (០១) រូប អនុប្រធានមួយ (០១) រូប អគ្គលេខាធិការមួយ (០១) រូប ហេរញ្ញិកមួយ (០១) រូប និង សមាជិកប្រាំ (០៥) រូប ។

**មាត្រា ២១.-**

ប្រធាន គ.ឆ.ខ. ប្រធាន គ.ឆ.ត. និងអគ្គលេខាធិការនៃក្រុមប្រឹក្សាទាំងនេះមិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

**មាត្រា ២២.-**

អង្គប្រជុំ គ.ឆ.ត. ត្រូវបានចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់ដោយ ÷

-តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ

-ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយប្រធានតុលាការនៃខេត្ត ក្រុងនោះ

-ឆ្មបការងារមួយរូប បើមានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ។

**មាត្រា ២៣.-**

នៅក្នុងក្របខ័ណ្ឌគណៈឆ្មបភូមិភាគ គ.ឆ.ត. អនុវត្តន៍ការងាររបស់ខ្លួនតែទៅលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

គ.ឆ.ត. អាចទទួលពាក្យប្តឹងជំទាស់ពី គ.ឆ.ជ. គ.ឆ.ខ. សមាគមឆ្មប រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធរខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ឬ សាមីឆ្មប ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប ។

គ.ឆ.ត. ត្រូវពិនិត្យសម្រេចនៅក្នុងរយៈពេលប្រាំមួយ (០៦) ខែយ៉ាងយូរ ក្រោយបានទទួលពាក្យប្តឹង ។ បើមិន ដូច្នេះទេ គ.ឆ.ជ. អាចបញ្ជូនពាក្យប្តឹងនេះទៅ គ.ឆ.ត. ណាមួយផ្សេងទៀតដែលបានជ្រើសរើស ។

**មាត្រា ២៤.-**

ឆ្មបដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបនឹងអាចបកស្រាយចំពោះមុខ គ.ឆ.ត. បានចំពោះសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួន តែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ឬ តាមរយៈព្រះរាជអាជ្ញាអមតុលាការតែប៉ុណ្ណោះ ។

**មាត្រា ២៥.-**

ការដាក់វិន័យត្រូវធ្វើឡើងនៅចំពោះមុខឆ្មបសាមី ។ ឆ្មបសាមីអាចមានអ្នកការពារដែលជាឆ្មប

ឬ ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ បើឆ្មបសាមីមិនព្រមចូលខ្លួនមកចំពោះ គ.ឆ.ត. តាមការអញ្ជើញចំនួនបី (០៣) លើក ដោយគ្មានមូលហេតុច្បាស់លាស់ គ.ឆ.ត. នឹងអនុវត្តតាមចំណុចទី៤ ក្នុងមាត្រា២៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ២៦ .-**

គ.ឆ.ត. ត្រូវមានបញ្ជីកត់ត្រានូវរាល់ការប្រជុំដាក់វិន័យ ។ គ.ឆ.ត. ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវ ដោយមានការបញ្ជាក់ និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវចោទសួរនោះផង ។

**មាត្រា ២៧.-**

គ.ឆ.ត.ដោយមានការចូលរួមពីផ្នែកវិន័យនៃគ.ឆ.ជ.អាចដាក់វិន័យដល់សមាជិកដូចខាងក្រោម÷

១- ការព្រមាន។

២-សេចក្តីបន្ទោសដោយកត់ទុកនៅក្នុងឯកសារផ្ទាល់ខ្លួន។

៣-ហាមប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពីបី (០៣) ឆ្នាំ ឬ ជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬ ជាទូទៅ នៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រដែលរដ្ឋទទួលស្គាល់ ។

៤-ការលុបឈ្មោះចេញពីបញ្ជីគណៈឆ្មប។

ឆ្មបដែលត្រូវលុបឈ្មោះចេញពីក្នុងបញ្ជីគណៈឆ្មប មិនអាចសុំចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីដែលបានសម្រេចចុងក្រោយដែលបានលើកឡើង ត្រូវតែផ្សព្វផ្សាយទៅគ្រប់ គ.ឆ.ខ. ព្រមទាំងទៅ គ.ឆ.ជ. ។ ការសម្រេចរបស់ គ.ឆ.ត. ត្រូវតែមានហេតុផលច្បាស់លាស់។

**មាត្រា ២៨.-**

ក្រោយបានទទួលវិន័យហាមប្រកបវិជ្ជាជីវៈអស់រយៈកាលបី (០៣) ឆ្នាំយ៉ាងតិចមក ឆ្មបដែលទទួលវិន័យ អាចទទួលការលើកលែងវិន័យពីក្រុមប្រឹក្សាគណៈឆ្មប ដែលបានដាក់វិន័យដល់ខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយឆ្មបសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះ ត្រូវបានបដិសេធក្រោយពីបានធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសារជាថ្មី នឹងអាចធ្វើទៅបានតែក្នុងរយៈកាល មួយ (០១)ឆ្នាំ ទៅមុខទៀត ។

ចំពោះវិន័យអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬ ជាទូទៅនៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់ មិនអាចស្នើសុំលើកលែងបានទេ។

**មាត្រា ២៩.-**

ការអនុវត្តវិន័យរបស់ឆ្មប មិនមែនជាឧបសគ្គរាំងដល់ការអនុវត្តការដាក់វិន័យខាងរដ្ឋបាល ឬ តុលាការឡើយ ។

## ផ្នែកទី៣

## ក្រុមប្រឹក្សាគណៈឆ្មបជាតិ (ក.ឆ.ជ.)

**មាត្រា ៣០.-**

ក.ឆ.ជ. ត្រូវបានជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេលប្រាំមួយ(០៦)ឆ្នាំ បែងចែកដូចខាងក្រោម ÷

-តំណាងឱ្យខេត្ត ក្រុង នីមួយៗចំនួនមួយ (០១) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកគណៈឆ្មប ខេត្ត ក្រុងនោះ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង

-តំណាងឱ្យរាជធានីភ្នំពេញចំនួនពីរ (០២) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកគណៈឆ្មបរាជធានីភ្នំពេញ ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំង ដោយប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

- តំណាងឱ្យអង្គភាពថ្នាក់កណ្តាលចំនួនប្រាំ (០៥) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម សមាជិកឆ្មបថ្នាក់កណ្តាល និងបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-តំណាងឱ្យសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រចំនួនមួយ(០១)រូប ជ្រើសរើសដោយការបោះឆ្នោត តែងតាំងដោយសាកលវិទ្យាធិការ ។

**មាត្រា ៣១.-**

ក.ឆ.ជ. ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី (១/៣) ក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិកមួយភាគបី (១/៣) ម្តងៗ ក្រុមប្រឹក្សាគណៈឆ្មបជាតិ ត្រូវធ្វើការជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួនសម្រាប់ពីរ (០២) ឆ្នាំម្តង ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈឆ្មបជាតិកម្ពុជា រួមមាន : ប្រធានក្រុមប្រឹក្សាមួយ (០១)រូប អនុប្រធានចំនួនពីរ (០២)រូប អគ្គលេខាធិការមួយ (០១)រូប អគ្គលេខាធិការរងមួយ(០១)រូប ហិរញ្ញិក មួយ (០១)រូប និងហេរញ្ញិករងមួយ (០១) រូប ។ ប្រធាន និង សមាជិក ក.ឆ.ជ. ដែលចេញពីតំណែងអាចឈរឈ្មោះឱ្យគេជ្រើសរើសសារជាថ្មីបាន ។

**មាត្រា ៣២.-**

ក.ឆ.ជ. មានជំនួយការជាឆ្មប ចំនួនពីរ (០២) រូប តំណាងឱ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មួយ (០១)រូប និងតំណាងឱ្យរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈមួយ (០១) រូប មានសម្លេងពិគ្រោះយោបល់ ។

**មាត្រា ៣៣.-**

ក.ឆ.ជ. មានផ្នែកវិន័យមួយដែលមានសមាជិក(០៧)រូប ដឹកនាំដោយប្រធានមួយ (០១) រូប ជ្រើសតាំងក្នុងចំណោមសមាជិកប្រាំពីរ (០៧) រូបនេះ ។ សមាជិកផ្នែកវិន័យ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតក្នុងចំណោមសមាជិកការិយាល័យនៃក្រុមប្រឹក្សា ក.ឆ.ជ. ។

ផ្នែកវិន័យមានភារកិច្ចដូចបានកំណត់ក្នុងមាត្រា ២៣ និងមាត្រា ២៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៤.-**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី ១/៣ របស់ខ្លួន គ.ឆ.ជ. ត្រូវធ្វើការជ្រើសតាំងផ្នែកវិន័យសារជាថ្មី ។

**មាត្រា ៣៥.-**

គ.ឆ.ជ. បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួន ពេលបំពេញបេសកកម្ម ដូចមានចែងនៅក្នុងមាត្រា ២ នៃព្រះរាជក្រឹត្យនេះ ។

គ.ឆ.ជ. ឃ្លាំមើលជាអាទិ៍ ការគោរពអនុវត្តតាម របស់សមាជិកនៃគណៈឆ្មបទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងក្រមសីលធម៌ឆ្មប ។

គ.ឆ.ជ. សហការជាមួយ គ.ឆ.ខ. ធ្វើការសិក្សាដោះស្រាយនូវបញ្ហាសុគ្រស្មាញទាំងឡាយដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ឆ្មប ។

គ.ឆ.ជ. បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សានូវបណ្តាបញ្ហា ឬ គម្រោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា ៣៦ .-**

គ.ឆ.ជ. ត្រូវកំណត់អំពីចំនួនទឹកប្រាក់វិភាគទានឯកភាពមួយ ដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

គ.ឆ.ជ. ត្រូវកម្រិតផងដែរ នូវចំនួនវិភាគទានដែល គ.ឆ.ខ. ត្រូវបង់ជូនទៅ គ.ឆ.ជ. ទៅ គ.ឆ.គ. និង ត្រូវរក្សាទុកនៅក្នុង គ.ឆ.ខ. ដើម្បីជានាចំណាយក្នុងការបំពេញការងារជាទូទៅ ។ ការបង់វិភាគទានគឺជាកាតព្វកិច្ច របស់សមាជិកម្នាក់ៗ ។

គ.ឆ.ជ. គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈឆ្មប និងអាចបង្កើត ឬ ឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយ ដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈឆ្មប ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

គ.ឆ.ជ.ត្រួតពិនិត្យការគ្រប់គ្រងរបស់គ.ឆ.ខ.និងគ.ឆ.គ.។ គ.ឆ.ខ. ត្រូវរាយការណ៍ជូនគ.ឆ.ជ. ជាមុន និងចម្លងជូនទៅ គ.ឆ.គ. ចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា ៣៧.-**

គ.ឆ.ជ. ត្រូវបង្កើតគណៈកម្មការសម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង។ សមាជិកនៃ គណៈកម្មការនេះត្រូវជ្រើសរើសដោយ គ.ឆ.ជ. ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យ នៃ ក្រុមប្រឹក្សា និងផ្នែកវិន័យ ។

ក្នុងបំណាច់ឆ្នាំនីមួយៗ គណៈកម្មការនេះ ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន គ.ឆ.ជ. ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

ក្នុងអាណត្តិទី ១ នេះ សមាសភាព គ.ឆ.ជ. ត្រូវបានជ្រើសតាំង និងឯកភាពដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីដំណើរការឱ្យមានប្រសិទ្ធភាព ។

ក្នុងអំឡុងពេលប្រាំមួយ ( ០៦ ) ឆ្នាំដំបូងនៃអាណត្តិទី ១ សមាសភាពការិយាល័យរបស់គ.ឆ.ខ. គ.ឆ.ត. ត្រូវបានជ្រើសតាំងដោយសហភាគរ:របស់ខ្លួន និងទទួលស្គាល់ដោយ គ.ឆ.ជ. ។

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវតែងតាំងក្រុមការងារមួយជាមណ្ឌោះអាសន្នដើម្បីរៀបចំដំណើរការ បង្កើតគណៈឆ្មបកម្ពុជា។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤១.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសម្តេច**

**ប្រមុខរដ្ឋស្តីទី**

**មន្ត្រីលេខា និងព្រះរាជលញ្ចករ**

**ជា ស៊ីម**

៣៣.០៦០៩.៤១៣

លេខ : ៣៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថន

# អនុក្រឹត្យស្តីពីក្រុមសីលធម៌ឆ្មប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ក្រុមសីលធម៌ឆ្មប

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរំលូតកូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៦/៣៨៩ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈឆ្មបកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ [illegible]

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់សីលធម៌ សេចក្តីថ្លៃថ្នូរ ភាពសុចរិត ប្រសិទ្ធភាព វិន័យការងារ ក្នុងការប្រកបវិជ្ជាជីវៈរបស់ឆ្មប និងជាពិសេសទទួលបានទំនុកចិត្តពីសាធារណជន។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្រមសីលធម៌វិជ្ជាជីវៈឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះឆ្មបទាំងអស់ ដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈឆ្មបពីក្រសួងសុខាភិបាល។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

ឆ្មបសំដៅដល់នីតិជនដែលមានសញ្ញាបត្រឆ្មបចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាបត្រឆ្មបចេញដោយគ្រឹះស្ថានសិក្សាដែលបានទទួលស្គាល់គុណភាពអប់រំដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

វិជ្ជាជីវៈឆ្មបសំដៅដល់ការផ្តល់សេវាថែទាំ ការគាំទ្រ ការផ្តល់ដំបូន្មានចាំបាច់ក្នុងអំឡុងពេលមានគភ៌ ពេលសម្រាល និងក្រោយពេលសម្រាល និងការផ្តល់សេវាសម្រាលដោយទទួលខុសត្រូវរួមទាំងផែនការគ្រួសារនិងពន្យារកំណើត ការរំលូតប្រកបដោយសុវត្ថិភាព ព្រមទាំងការថែទាំទារកទើបនឹងកើតផង។

គ្រឹះស្ថានឆ្មបសំដៅដល់កន្លែងដែលឆ្មបបម្រើការងារឆ្មប ដូចជា មន្ទីរពេទ្យ មន្ទីរសម្ភព មណ្ឌលសុខភាព គ្លីនិក និងបន្ទប់ថែទាំឯកជន ដែលមានការទទួលស្គាល់ឬការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី២

## ករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ឆ្មប

**មាត្រា ៥.-**

ដើម្បីសម្រេចករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ខ្លួន ឆ្មប៖

១- ត្រូវបំពេញការងារដោយមានការទទួលខុសត្រូវនិងមានគណនេយ្យភាព ហើយធ្វើការជាដៃគូជាមួយស្ត្រី ដៃគូគ្រួសារ និងអាណាព្យាបាលរបស់គាត់។

២- ត្រូវបំពេញការងារដោយគោរពតាមច្បាប់ បទប្បញ្ញត្តិជាធរមាន គោលការណ៍ណែនាំជាតិ និងពិធីសារជាតិដែលទាក់ទងនឹងវិជ្ជាជីវៈឆ្មប។

៣- ត្រូវប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវឥស្សរភាពវិជ្ជាជីវៈ នៅគ្រប់កាលៈទេសៈទាំងអស់។

៤- ត្រូវចូលរួមអនុវត្តគោលនយោបាយយុទ្ធសាស្ត្រជាតិឱ្យមានប្រសិទ្ធភាពនិងសហការគ្នាក្នុងការប្រកបវិជ្ជាជីវៈឆ្មប ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សុខភាពមាតានិងទារក។

៥- ត្រូវផ្តល់សេវាប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ដោយមានគុណធម៌ អាកប្បកិរិយាល្អ សម្តីសុភាពរាបសា ត្រឹមត្រូវ និងយកចិត្តទុកដាក់។

៦- ត្រូវអភិវឌ្ឍសមត្ថភាពខ្លួនជាប្រចាំ តាមរយៈការចូលរួមបណ្តុះបណ្តាលបន្ត ការស្រាវជ្រាវ ការទទួលព័ត៌មានបន្ថែមថ្មីៗ។

៧- ត្រូវអភិវឌ្ឍវិជ្ជាជីវៈឆ្មបតាមរយៈការចូលរួមរៀបចំនិងកែលម្អពិធីសារជាតិ គោលការណ៍ណែនាំជាតិ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

៨- ត្រូវគោរពជីវិត រាងកាយ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី នៅពេលផ្តល់សេវា។

៩- ត្រូវគោរពការសម្ងាត់វិជ្ជាជីវៈនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា ដើម្បីរក្សាភាពជាឯកជន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី។

១០- ត្រូវគោរពសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសឆ្មបនិងត្រូវជួយសម្របសម្រួលដល់ស្ត្រីក្នុងការជ្រើសរើសឆ្មបដោយឆន្ទៈរបស់សាមីខ្លួន។

១១- ត្រូវផ្តល់សេវាចំពោះស្ត្រី ដោយគ្មានការរើសអើងចំពោះពូជសាសន៍ ពណ៌សម្បុរ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

១២- ត្រូវចូលរួមផ្តល់មតិដើម្បីការពារសិទ្ធិរបស់ស្ត្រី គ្រួសារ និងសហគមន៍ដែលមានទំនាក់ទំនងជាមួយនឹងការថែទាំសុខភាពមាតានិងទារក រាប់បញ្ចូលទាំងសិទ្ធិក្នុងការមានផ្ទៃពោះ។

**មាត្រា ៦.–**

ឆ្មបផ្តល់ឱសថតាមវេជ្ជបញ្ជានិងតាមគោលការណ៍ណែនាំថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល។

**មាត្រា ៧.–**

ឆ្មបត្រូវស្ថិតនៅជាមួយស្ត្រីមានគភ៌ដែលហៀបនឹងសម្រាល កំពុងសម្រាល ទើបសម្រាលថ្មីៗ និងទារកទើបនឹងកើត។ ក្នុងករណីមាតានិង/ឬទារកស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឆ្មបត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងថែទាំទារក ឬត្រូវធ្វើការសង្គ្រោះបឋមនិងបញ្ជូនទៅសេវាឆ្មបឬសេវាសមស្របផ្សេងទៀតតាមការចាំបាច់។

**មាត្រា ៨.-**

ឆ្មបដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចសុំឱ្យពិនិត្យឬប្រឹក្សាយោបល់ទាក់ទងទៅនឹងវិជ្ជាជីវៈឆ្មបតាមរយៈអង្គភាពនិងស្ថាប័ន ដល់ស្ត្រីជាជនសង្ស័យនិងជនជាប់ឃុំ ត្រូវជូនដំណឹងត្រឡប់ដល់អាជ្ញាធរមានសមត្ថកិច្ចពីស្ថានភាពសុខភាពរបស់ស្ត្រី។

**មាត្រា ៩.-**

ដើម្បីអនុវត្តករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ខ្លួនឱ្យបានល្អ ឆ្មបៈ

១- មិនត្រូវធ្វើការងារណាដែលនាំឱ្យប៉ះពាល់ អាប់ឱនកិត្តិយស និងសេចក្តីថ្លៃថ្នូរដល់វិជ្ជាជីវៈឆ្មបឡើយ។

២- មិនត្រូវប្រើឥទ្ធិពលរបស់ខ្លួនដើម្បីទទួលបាននូវកិច្ចសន្យា បុព្វសិទ្ធិ សិទ្ធិឬផលប្រយោជន៍ពីអ្នកជំងឺ។

៣- មិនត្រូវប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ជាមួយនឹងគ្រឹះស្ថានឆ្មបក្នុងការបញ្ជូនស្ត្រីដើម្បីប្រាក់កម្រៃជើងសាឬថ្លៃសេវាឡើយ។

៤- មិនត្រូវបំពេញការងារឆ្មបនៅទីសាធារណៈ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

៥- មិនត្រូវចេញវិញ្ញាបនបត្រនិងលិខិតបញ្ជាក់ផ្សេងៗដែលទាក់ទងនឹងវិជ្ជាជីវៈឆ្មប។

៦- មិនត្រូវទារថ្លៃសេវាហួសកម្រិតឬផ្តល់ព័ត៌មានក្លែងក្លាយទាក់ទងនឹងកម្រៃសេវារបស់ខ្លួន។

៧- មិនត្រូវប្រើរហស្សនាមក្នុងការប្រកបវិជ្ជាជីវៈឆ្មប។

៨- មិនត្រូវផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មអំពីសេវារបស់ខ្លួនដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។

៩- មិនត្រូវបង្ហាញអត្តសញ្ញាណរបស់ស្ត្រីតាមរយៈការផ្សព្វផ្សាយជាសាធារណៈឬក្នុងគោលបំណងវេជ្ជសាស្ត្រឡើយ លើកលែងតែមានការយល់ព្រមពីស្ត្រីដែលជាសាមីខ្លួន។

១០-មិនត្រូវបានអនុញ្ញាតឱ្យចេញវេជ្ជបញ្ជាទូទៅឬលក់ឱសថឡើយ។

១១-មិនត្រូវផ្តល់សេវាឬប្រឹក្សាយោបល់ក្រៅពីវិជ្ជាជីវៈឆ្មបដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនឡើយ លើកលែងតែក្នុងករណីចាំបាច់ដែលត្រូវសង្គ្រោះបន្ទាន់។

**មាត្រា ១០.-**

ឆ្មបដែលមានតួនាទីក្នុងអាណត្តិជាប់ឆ្នោតឬតំណែងផ្លូវការណាមួយ មិនត្រូវប្រើតួនាទីនោះដើម្បីទាក់ទាញអតិថិជនឡើយ។

## ជំពូកទី៣
## ទំនាក់ទំនងរវាងឆ្មបនិងស្ត្រីឬអតិថិជន

**មាត្រា ១១._**

ក្នុងករណីដែលស្ត្រី គ្រួសារ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់បដិសេធការព្យាបាលឬការថែទាំសុខភាព ឆ្មបត្រូវគោរពតាមការសម្រេចចិត្តរបស់អ្នកទាំងនោះ តែត្រូវពន្យល់អំពីផលវិបាកនានាដែលអាចកើតមានឡើង។

**មាត្រា ១២._**

ឆ្មបត្រូវជូនដំណឹងអំពីស្ថានភាពសុខភាពឬការវិវត្តនៃជំងឺដល់ស្ត្រី។ ការផ្តល់ដំណឹងដល់ប្តី ដៃគូ គ្រួសារ ឬតំណាងស្របច្បាប់ ត្រូវមានការយល់ព្រមពីសាមីខ្លួន។

**មាត្រា ១៣._**

ឆ្មបអាចបដិសេធមិនផ្តល់សេវាឆ្មបដល់ស្ត្រីណាម្នាក់ ដោយមានហេតុផលវិជ្ជាជីវៈឬហេតុផលផ្ទាល់ខ្លួនបាន លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។ ប្រសិនបើសេវាឆ្មបត្រូវបានបដិសេធបែបនេះ ឆ្មបត្រូវបញ្ជូនស្ត្រីទៅកាន់សេវាជំនួសផ្សេងទៀត។

**មាត្រា ១៤._**

ឆ្មបដែលត្រូវពិនិត្យអនីតិជនឬអសមត្ថជនពេញវ័យ ត្រូវជូនដំណឹងដល់ឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់របស់ជននោះ ហើយឆ្មបត្រូវស្វែងរកការយល់ព្រមពីអ្នកទាំងនោះនៅមុនពេលចាប់ផ្តើមផ្តល់សេវា។

ក្នុងករណីបន្ទាន់ដែលអាចគ្រោះថ្នាក់ដល់ជីវិត ទោះបីជាមិនអាចធ្វើការទាក់ទងនឹងអ្នកទាំងនោះបានក៏ដោយ ក៏ឆ្មបត្រូវតែផ្តល់សេវាជាចាំបាច់ដោយមានវត្តមាននិងការឯកភាពពីអ្នករួមការងារ។

ប្រសិនបើសាមីជនអាចបញ្ចេញមតិបាន ឆ្មបត្រូវពិចារណាដល់មតិនេះ បើអាចធ្វើទៅបាន។

**មាត្រា ១៥._**

ឆ្មបត្រូវផ្តល់ការការពារពិសេសចំពោះអនីតិជនឬអសមត្ថជនពេញវ័យ ប្រសិនបើអ្នកទាំងនោះមិនទទួលបានការថែទាំព្យាបាល ឬផលប្រយោជន៍ និងសិទ្ធិខាងសុខភាពបានត្រឹមត្រូវ។

ក្នុងករណីបែបនេះ ឆ្មបត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

**មាត្រា ១៦._**

ឆ្មបឬគ្រឹះស្ថានឆ្មបត្រូវបង្ហាញតម្លៃសេវាទៅលើការពិនិត្យ ការពិគ្រោះយោបល់ ការថែទាំការព្យាបាល និងការផ្តល់សេវាដទៃទៀត។

ឆ្មបអាចជូនដំណឹងដល់អ្នកជំងឺអំពីតម្លៃនិងការចំណាយចាំបាច់ផ្សេងៗមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

**មាត្រា ១៧.-**

ក្នុងករណីមានគ្រោះថ្នាក់ក្នុងទីសាធារណៈ ឆ្មបមិនត្រូវបោះបង់ស្ត្រីនិងទារកនោះទេ លើកលែងតែមានបទបញ្ជាណាមួយពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមលក្ខខណ្ឌច្បាប់។

**មាត្រា ១៨.-**

ឆ្មបមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការគ្រួសារឬក្នុងជីវភាពផ្ទាល់ខ្លួនរបស់ស្ត្រីឡើយ បើពុំមានមូលហេតុវិជ្ជាជីវៈ។

## ជំពូកទី៤
## ទំនាក់ទំនងរវាងឆ្មបនិងសហភាគរៈ
## រវាងឆ្មបនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត

**មាត្រា ១៩.-**

ឆ្មបត្រូវពង្រឹងទំនាក់ទំនងល្អជាមួយសហភាគរៈ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត តាមរយៈការជំរុញ ការគាំទ្រគ្នាទៅវិញទៅមក ដើម្បីជាផលប្រយោជន៍ដល់ការថែទាំសុខភាពសាធារណៈ សុខុមាលភាពសហគមន៍និងកន្លែងធ្វើការ។

**មាត្រា ២០.-**

ឆ្មបត្រូវអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយសហការជាមួយ ឬស្វែងរកដំបូន្មាន ឬសុំជំនួយពីឆ្មបដទៃឬពីគ្រូពេទ្យជំនាញតាមស្ថានភាពសមស្រប លើកលែងតែក្នុងករណីដែលការងារនោះផ្ទុយនឹងវិជ្ជាជីវៈឆ្មប។

**មាត្រា ២១.-**

នៅពេលទទួលបានការប្រគល់ដើម្បីផ្តល់សេវាចំពោះស្ត្រី ដែលសហភាគរៈម្នាក់ទៀតបានផ្តល់សេវារួចហើយ៖

- ឆ្មបជំនួសត្រូវទទួលបានការយល់ព្រមជាមុនពីស្ត្រី
- ឆ្មបជំនួសត្រូវទាក់ទងជាមួយឆ្មបមុន ដើម្បីស្វែងរកយោបល់ឬដំបូន្មាន មុននឹងបន្តផ្តល់សេវាក្នុងការពិនិត្យថែទាំដល់ស្ត្រី
- នៅពេលបញ្ចប់ការជំនួស ឆ្មបជំនួសត្រូវបញ្ឈប់សកម្មភាពពាក់ព័ន្ធនឹងការជំនួសទាំងអស់ និងប្រគល់ព័ត៌មានចាំបាច់ផ្សេងៗដល់ឆ្មបមុន ដើម្បីនិរន្តភាពនៃការថែទាំព្យាបាល។

**មាត្រា ២២.-**

ឆ្មបត្រូវគ្រប់គ្រងនិងទទួលខុសត្រូវលើនិស្សិតអន្តេវាសិកឆ្មបដែលកំពុងបំពេញការងារក្នុងកន្លែងធ្វើការរបស់ខ្លួន។

**មាត្រា ២៣.-**

ឆ្មបមិនត្រូវបង្កើតក្រុមឬបណ្តាញក្នុងគោលបំណងដើម្បីរើសអើងសហភាគរៈឡើយ។

**មាត្រា ២៤.-**

ឆ្មបមិនត្រូវធ្វើអ្វីដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ឆ្មបណាម្នាក់ឡើយ។

## ជំពូកទី៥
## ការប្រកបវិជ្ជាជីវៈឆ្មប

**មាត្រា ២៥.-**

ឆ្មបអាចបោះពុម្ពអត្តសញ្ញាណផ្ទាល់ខ្លួននិងព័ត៌មានមួយចំនួនដោយសុចរិតទៀងត្រង់ដូចខាងក្រោមនេះ៖

១- នាមត្រកូល  នាមខ្លួន គុណវុឌ្ឍិ លេខចុះបញ្ជីក្នុងគណៈឆ្មបកម្ពុជា អាសយដ្ឋានប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល គេហទំព័រ ថ្ងៃ និងពេលវេលាសម្រាប់ធ្វើការប្រឹក្សា។

២- នាមត្រកូលនិងនាមខ្លួនរបស់ឆ្មបទាំងអស់ក្នុងក្រុម ប្រសិនបើឆ្មបប្រកបមុខរបរជាក្រុម។

**មាត្រា ២៦.-**

ការបញ្ជាក់មួយចំនួនដែលឆ្មបឬគ្រឹះស្ថានឆ្មបត្រូវបានអនុញ្ញាតឱ្យសរសេរនៅលើស្លាកកន្លែងធ្វើការមាន៖

១- នាមត្រកូលនិងនាមខ្លួន លេខចុះបញ្ជីឆ្មបក្នុងគណៈឆ្មបកម្ពុជា អាសយដ្ឋានប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល គេហទំព័រ។

២- នាមត្រកូលនិងនាមខ្លួន និងលេខចុះបញ្ជីឆ្មបក្នុងគណៈឆ្មបកម្ពុជានៃឆ្មបទាំងអស់ដែលប្រកបវិជ្ជាជីវៈនៅក្នុងគ្រឹះស្ថានឆ្មបនោះ។

៣- តារាងកំណត់តម្លៃសេវាពិនិត្យសុខភាព។

**មាត្រា ២៧.-**

ឆ្មបត្រូវបានអនុញ្ញាតឱ្យធ្វើការនៅស្ថាប័នឯកជន ក្នុងនាមជាឆ្មបឯកជន។

ប្រសិនបើឆ្មបធ្វើការនៅស្ថាប័នរដ្ឋផងនិងស្ថាប័នឯកជនផង ការងារឯកជនមិនត្រូវប៉ះពាល់ដល់ការងាររដ្ឋរបស់ខ្លួនឡើយ។

**មាត្រា ២៨.-**

ឆ្មបដែលផ្តល់សេវា ហើយកំពុងមានបញ្ហាជាមួយស្ត្រីទទួលសេវា មិនអាចធ្វើជាសមាជិកគណៈកម្មការវិន័យឡើយ ។

ឆ្មបដែលធ្វើការនៅគ្រឹះស្ថានឆ្មបជាមួយគ្នា ឬជាញាតិលោហិតផ្ទាល់ ឬជាញាតិពន្ធក្នុង៣ថ្នាក់របស់ឆ្មប ឬមានទំនាក់ទំនងជាមួយនឹងឆ្មបដែលកំពុងជាប់ពាក់ព័ន្ធក្នុងសកម្មភាពដាក់វិន័យ មិនអាចជាសមាជិកគណៈកម្មការវិន័យឡើយ។

**មាត្រា ២៩.–**

ឆ្មបដែលជាសមាជិកគណៈកម្មការវិន័យត្រូវឯករាជ្យនៅក្នុងមុខងារ ត្រូវមានសមត្ថភាពក្នុងការបញ្ចេញទស្សនៈពាក់ព័ន្ធនឹងការវិភាគនិងការស្វែងរកដំណោះស្រាយចំពោះករណីដែលត្រូវត្រួតពិនិត្យ។

ឆ្មបមិនត្រូវលម្អៀងក្នុងការបង្ហាញហេតុផលឬធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធ ចំពោះករណីដែលខ្លួនត្រូវត្រួតពិនិត្យនោះទេ។

**មាត្រា ៣០.–**

ឆ្មបត្រួតពិនិត្យមិនត្រូវជ្រៀតជ្រែកឬកែប្រែការថែទាំព្យាបាលឡើយ លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះកំណត់ដោយច្បាប់។

**មាត្រា ៣១.–**

ឆ្មបត្រួតពិនិត្យត្រូវគោរពការសម្ងាត់វិជ្ជាជីវៈតាមបទប្បញ្ញត្តិដែលបានចែង។ របាយការណ៍ឬឯកសារដែលមានសម្គាល់អត្តសញ្ញាណរបស់ស្ត្រីទទួលសេវាឬរបស់ឆ្មបពិនិត្យថែទាំព្យាបាល មិនត្រូវបង្ហាញដល់ស្ថាប័នដែលមិនពាក់ព័ន្ធឬសាធារណជនឡើយ។

## ជំពូកទី៦
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ៣២.–**

ឆ្មបទាំងអស់ នៅពេលសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប ត្រូវបញ្ជាក់នៅចំពោះមុខក្រុមប្រឹក្សាគណៈឆ្មបរាជធានី ខេត្តថាខ្លួនបានយល់ដឹងច្បាស់លាស់ពីអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មបនេះរួចហើយ និងសន្យាជាលាយលក្ខណ៍អក្សរថាគោរពតាមក្រមសីលធម៌នេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**មាត្រា ៣៣.–**

ឆ្មបដែលផ្តល់សេចក្តីបញ្ជាក់មិនត្រឹមត្រូវឬមិនពេញលេញដោយចេតនា ធ្វើឡើងជូនក្រុមប្រឹក្សាគណៈឆ្មប រាជធានី ខេត្ត អាចនាំឱ្យមានការចោទប្រកាន់ខាងវិន័យ។

**មាត្រា ៣៤.–**

ឆ្មបដែលឈប់ប្រកបមុខរបរឬកែប្រែលក្ខខណ្ឌនៃការប្រកបមុខរបរ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈឆ្មប រាជធានី ខេត្ត។ ក្រុមប្រឹក្សាគណៈឆ្មបរាជធានី ខេត្ត ដែលទទួលដំណឹងអំពីការឈប់ឬការកែប្រែនេះ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈឆ្មបជាតិ។

**មាត្រា ៣៥.-**

សេចក្តីសម្រេចទាំងឡាយរបស់គណៈឆ្មបគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តតាមអនុក្រឹត្យនេះ ត្រូវតែមានមូលហេតុច្បាស់លាស់។

**មាត្រា ៣៦.-**

ក្នុងករណីដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈឆ្មបរាជធានី ខេត្ត ស្ត្រីទទួលសេវាឬឆ្មបដែលផ្តល់សេវាមានរយៈពេល២ខែ ដើម្បីសុំឱ្យក្រុមប្រឹក្សាគណៈឆ្មបជាតិពិនិត្យសេចក្តីសម្រេចនោះឡើងវិញ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## សំនួរជាញឹកញាប់អំពីគណៈឆ្មបកម្ពុជា

| ល.រ | សំណួរ | ចម្លើយ |
|---|---|---|
| ១ | តើគណៈឆ្មបកម្ពុជាគឺជាអ្វី? | គណៈឆ្មបកម្ពុជា(គ.ឆ.ក)ជាអង្គការស្វយ័តមួយដែលបានត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៦/៣៨៩ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៦ក្នុងគោលបំណងការពារសាធារណជន និងឆ្មបដែលអនុវត្តត្រឹមត្រូវ។ |
| ២ | តើគ.ឆ.កមានតួនាទីអ្វីខ្លះក្នុងការចូលរួមកាត់បន្ថយអត្រាមរណភាពមាតា-ទារក? | តួនាទីរបស់គ.ឆ.កមានដូចតទៅៈ<br><br>១. ចុះបញ្ជីឆ្មបៈ ដើម្បីធានាថាឆ្មបមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសុខភាពល្អ និងមានសីលធម៌ល្អ ដើម្បីអនុវត្តការងារឆ្មប។<br><br>២. ចុះបញ្ជីឆ្មបសារឡើងវិញៈ ដើម្បីធានាថាចំណេះដឹងនិងជំនាញរបស់ឆ្មបបានធ្វើបច្ចុប្បន្នភាពតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈបន្ត។<br><br>៣. រៀបចំបទដ្ឋានសម្រាប់ការអនុវត្តនិងក្រមសីលធម៌ឆ្មបដូចជាៈ ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់ឆ្មបវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជានិងចូលរួមរៀបចំបទដ្ឋានសម្រាប់ការបណ្តុះបណ្តាលមូលដ្ឋាននិងបន្ត។ល។<br><br>៤. ដោះស្រាយពាក្យបណ្តឹងនិងដាក់វិន័យឆ្មបដែលមិនគោរពតាមបទដ្ឋាននិងក្រមសីលធម៌ឆ្មប។ |

| | | |
|---|---|---|
| ៣ | ហេតុអ្វីធ្មបចាំបាច់ត្រូវតែចុះបញ្ជីជាមួយគណៈធ្មបកម្ពុជា? | មាត្រាទី១នៃ ព្រះរាជក្រឹត្យលេខនស/រកត/០៩០៦/៣៨៩ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៦ ធ្មបទាំងអស់ដែលប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈធ្មប។ |
| ៤ | តើអ្វីទៅជាអត្ថប្រយោជន៍នៃការចុះបញ្ជីជាមួយគ.ឆ.ក? | បន្ទាប់ពីបានចុះបញ្ជីជាមួយគ.ឆ.ក ធ្មបនឹងក្លាយជា "ធ្មបវិជ្ជាជីវៈស្របច្បាប់" និងបញ្ជាក់ជូនសាធារណជនថាខ្លួនបានបំពេញតាមបទដ្ឋានដែលកំណត់ដោយគ.ឆ.ក។ |
| ៥ | តើធ្មបដែលចូលនិវត្តន៍ត្រូវបន្តចុះបញ្ជីជាមួយគ.ឆ.កដែរឬទេ? | ទេ ប្រសិនបើធ្មបមិនមានបំណងប្រកបវិជ្ជាជីវៈធ្មប។ |
| ៦ | តើគ.ឆ.កជួយអ្វីខ្លះដល់ធ្មបសមាជិកនៅពេលមានពាក្យបណ្តឹងលើធ្មប? | នៅពេលក្រុមប្រឹក្សាគណៈធ្មបភូមិភាគ(ក.ឆ.ភ) ទទួលបានពាក្យបណ្តឹងលើធ្មប ក.ឆ.ភនឹងស៊ើបអង្កេតដោយយុត្តិធម៌លើករណីនិងធ្វើការវិនិច្ឆ័យថាតើការអនុវត្តរបស់ធ្មបមានរំលោភលើបទដ្ឋានឬក្រមសីលធម៌ធ្មបឬអត់។ ប្រសិនបើលទ្ធផលការស៊ើបអង្កេតបញ្ជាក់ថាធ្មបមិនមានកំហុស ក.ឆ.ភនឹងបញ្ជូនរបាយការណ៍លទ្ធផលទៅស្ថាប័នពាក់ព័ន្ធដូចជាថ្នាក់លើធ្មប ក្រសួងសុខាភិបាល តុលាការ ឬនគបាល។ ប្រសិនបើករណីធ្ងន់ធ្ងររកឃើញថាធ្មបបានអនុវត្តន៍រំលោភបទដ្ឋានឬក្រមសីលធម៌ធ្មប ក.ឆ.ភនឹងអនុវត្តតាមមាត្រា២៧នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈធ្មបកម្ពុជា។ |

| | | |
|---|---|---|
| ៧ | ហេតុអ្វីឆ្មបត្រូវបង់ថវិកា២០,០០០ រៀលសម្រាប់ការចុះបញ្ជី និងបង់ប្រចាំឆ្នាំចំនួន២០,០០០រៀលដល់ គ.ឆ.ក? | គ.ឆ.កគឺជាអង្គការស្វយ័តដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់ការទទួលខុសត្រូវលើការឃ្លាំមើលការប្រព្រឹត្តទៅតាមក្រមសីលធម៌ និងបទដ្ឋានឆ្មបផ្សេងៗ។ មានន័យថាគ.ឆ.កត្រូវរ៉ាប់រងលើការចំណាយលើការងារគ្រប់គ្រងឆ្មបរបស់ខ្លួន។ដូច្នេះសមាជិកគ.ឆ.កទាំងអស់ត្រូវបង់ថវិកាវិភាគទានតាមការកំណត់ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក.ឆ.ជ ដោយយោងតាមមាត្រា៣៦នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឆ្មបកម្ពុជា។ |
| ៨ | តើឆ្មបអាចចុះបញ្ជីជាមួយគ.ឆ.ក នៅកន្លែងណា? | ឆ្មបត្រូវចុះបញ្ជីជាមួយក្រុមប្រឹក្សាគណៈឆ្មបរាជធានី-ខេត្តដែលខ្លួនកំពុងបំរើការងារ។ |
| ៩ | តើការចុះបញ្ជីត្រូវមានលក្ខខណ្ឌអ្វីខ្លះ? | លក្ខខណ្ឌមាន:<br>១. បំពេញពាក្យសុំចូលជាសមាជិក និងជីវប្រវត្តិសង្ខេប<br>២. មានសញ្ញាប័ត្រឆ្មប(បឋម មធ្យម ឬបរិញ្ញាប័ត្រ)<br>៣. មានសុខភាពល្អ(ផ្លូវកាយ និងចិត្ត)<br>៤.បង់ថវិកាចំនួន២០,០០០រៀលសម្រាប់ការចុះបញ្ជីនិង២០,០០០រៀលសម្រាប់វិភាគទានរៀងរាល់ប្រចាំឆ្នាំ។ |
| ១០ | តើឆ្មបត្រូវធ្វើដូចម្តេចនៅពេលខ្លួនផ្លាស់ប្តូរទីកន្លែងប្រកបវិជ្ជាជីវៈ? | ឆ្មបត្រូវចុះបញ្ជីជាមួយក.ឆ.ខថ្មីដែលខ្លួនត្រូវទៅនិងជូនដំណឹងដល់ក.ឆ.ខចាស់អំពីការផ្លាស់ទីតាំង |

| | | |
|---|---|---|
| | | របស់ខ្លួន។ |
| ១១ | តើការប្រមូលថវិកាចុះឈ្មោះចាប់ផ្តើមពីពេលណាមក? | គ.ឆ.ខចាប់ផ្តើមប្រមូលថវិកាប្រចាំឆ្នាំចាប់ពីឆ្នាំ២០១២មក។ |

## អំពីគណៈឆ្មបកម្ពុជា(គ.ឆ.ក)

គណៈឆ្មបកម្ពុជា (គ.ឆ.) ជាអង្គការស្វយ័តមួយដែលបានត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកត/០៩០៦/៣៨៩ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៦។

**ទស្សនៈវិស័យ**

ធានាថាឆ្មបទាំងអស់ផ្តល់សេវាថៃទាំសុខភាពដូចៗគ្នា ប្រកបដោយគុណភាព និងប្រសិទ្ធិភាពខ្ពស់ដល់ មាតានិងទារកទើបកើត តាមរយៈគោលនយោបាយនិងពិធីសារជាតិ ព្រមទាំងបទដ្ឋានអន្តរជាតិនៃការអនុវត្តវិជ្ជាជីវៈឆ្មប។

**បេសកកម្ម**

ឃ្លាំមើលរាល់ការប្រព្រឹត្តរបស់សមាជិកខ្លួនដោយបង្កើតនិងអនុវត្តន៍បទបញ្ញារួមមាន ការចុះបញ្ជី ការរៀបចំបទដ្ឋាននៃការអប់រំនិងអនុវត្តន៍ ដោះស្រាយការអនុវត្តមិនត្រឹមត្រូវ ដើម្បីលើកកំពស់បទដ្ឋាននៃការប្រកបវិជ្ជាជីវៈឆ្មប។

**គោលបំណង**

ផ្តល់សុវត្ថិភាពនិងការពារសុខភាពរបស់មាតានិងទារកទើបកើតដើម្បីចូលរួមកាត់បន្ថយអត្រាមរណភាពមាតានិងទារក។

**គុណតម្លៃ**

១. គោរពសិទ្ធិមនុស្ស និង ជាពិសេសគោរពសិទ្ធិសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ

២. ស្ត្រីជាមនុស្សសំខាន់បំផុតនៃការថែទាំរបស់ឆ្មប

៣. យុត្តិធម៌ សុចរិតភាព តម្លាភាព និង គណនេយ្យភាព

៤. ប្តេជ្ញាសម្រេច ឲ្យបាននូវគុណភាព

៥. ប្តេជ្ញាអភិវឌ្ឍន៍ វិជ្ជាជីវៈឆ្មបជាបន្ត

## គោលការណ៍នាំមុខ

គណៈឆ្មបកម្ពុជាប្រកាន់នូវគោលការណ៍នាំមុខក្នុងការផ្តល់ការថែទាំឆ្មបប្រកបដោយគុណភាពដែលមាន៖

១. **សុវត្ថិភាព:** ស្ត្រីនិងទារកមិនទទួលរងនូវគ្រោះថ្នាក់មិនសមហេតុផលផ្សេងៗពីការព្យាបាលនិងពីឥរិយាបថក្នុងពេលអនុវត្តន៍ការងារ

២. **ប្រសិទ្ធភាព:** រូបភាពនៃការ ថែទាំត្រូវផ្អែកលើការស្រាវជ្រាវរកឃើញថ្មី និង គោរពតាមគោលការណ៍ណែនាំថ្នាក់ជាតិ

៣. **ផ្តោតលើស្ត្រី:** ឆ្មបត្រូវឆ្លើយតប និងគោរពតម្លៃនិងជម្រើសរបស់ស្ត្រីដើម្បីធានាឲ្យបាននូវការពេញចិត្តនៅគ្រប់កាលៈទេសៈនៃការថែទាំសុខភាព

៤. **មធ្យោបាយនៃការបញ្ជូន:** ខិតខំប្រឹងប្រែងដើម្បីធានាផ្តល់សេវាទាន់ពេលវេលា និងមានតម្លៃសមស្រប

៥. **ប្រសិទ្ធផល:** ធនធានត្រូវបានប្រើប្រាស់សមស្រប ដើម្បី ធានាឲ្យប្រយោជន៍បានដល់ស្ត្រីនិងទារកជាអតិបរមា

៦. **សមធម៌:** សេវាឆ្មបអាចផ្តល់ជូនមនុស្សគ្រប់រូបដែលត្រូវការសេវានេះ

៧. **ប្តូរពីការស្តីបន្ទោសទៅជាការកែលំអ:** គណៈឆ្មប កម្ពុជានឹងចាត់ទុក ”ផ្នែកដែលមានបញ្ហា” ថាជា ”ឱកាសសម្រាប់ការកែលំអ” តាមរយៈពាក្យបណ្តឹង និងបទបញ្ហាផ្សេងៗទៀតរបស់ខ្លួន។

## ដំណើរការនៃការពិនិត្យពាក្យបណ្តឹង ការស៊ើបអង្កេត និង សវនាការរបស់ក្រុមប្រឹក្សាគណៈឆ្នបត្ដមិភាគនិងជាតិ

គណៈកម្មការស៊ើបអង្កេតពាក្យបណ្តឹងនិងសវនាការឆ្មបទទួលបានពាក្យបណ្តឹង

→ ករណីនោះត្រូវបានបិទបញ្ចប់ បើគ្មានករណីដែលត្រូវឆ្លើយ

↓

តែងតាំងអ្នកស៊ើបអង្កេត និងចាប់ផ្តើមការស៊ើបអង្កេត

↓

ផ្តល់ព័ត៌មានលម្អិតអំពីពាក្យបណ្តឹងដល់ឆ្មបដែលត្រូវគេប្តឹង ហើយឆ្មបមានរយៈពេល៩០ថ្ងៃដើម្បីឆ្លើយតប

↓

ឆ្មបគ្រប់រូបត្រូវបានផ្តល់សិទ្ធិឲ្យចូលរួមសវនាការនៅចំពោះមុខគណៈកម្មការស៊ើបអង្កេតពាក្យបណ្តឹងនិងសវនាការឆ្មប

↓

សេចក្តីសម្រេចរបស់គណៈកម្មការស៊ើបអង្កេតពាក្យបណ្តឹងឆ្មបត្រូវបានផ្ញើជូនទៅដើមបណ្តឹងនិងឆ្មប

↓

ឆ្មបទទួលយកសេចក្តីសម្រេចនិងវិន័យ

ឆ្មបនិងដើមបណ្តឹងមានសិទ្ធិប្តឹងជំទាស់នឹងសេចក្តីសម្រេចក្នុងរយៈពេល២ខែគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការស៊ើបអង្កេតពាក្យបណ្តឹងនិងសវនាការ

↓

ផ្នែកវិន័យរបស់ក.ឆ.ជបានទទួលពាក្យប្តឹងជំទាស់

↓

ផ្នែកវិន័យបើកសវនាការ និងជូនដំណឹងនូវសេចក្តីសម្រេចដល់គ្រប់ភាគីទាំងអស់ដែលពាក់ព័ន្ធ

## រចនាសម្ព័ន្ធរបស់គណៈឆ្មបកម្ពុជា

### <u>រចនាសម្ព័ន្ធក្រុមប្រឹក្សាគណៈឆ្មបជាតិ(ក.ឆ.ជ)</u>




**ផ្នែបណ្តុះបណ្តាល**

- ចូលរួមបង្កើតស្តង់ដារបណ្តុះបណ្តាលមូលដ្ឋាននិងបន្ត
- បង្កើតនិងធ្វើបច្ចុប្បន្នភាពក្របខណ្ឌសមត្ថភាពស្នូលសម្រាប់ឆ្មបវិជ្ជាជីវៈ

**ផ្នែកចុះបញ្ជីរ**

- រក្សាបញ្ជីរឈ្មោះនៅថ្នាក់ជាតិ(Database)
- ចុះបញ្ជីឆ្មបបរទេស
- រៀបចំនិតិវិធីស្តីពីការកំណត់ប្រភេទនិងលក្ខខណ្ឌនៃការចុះបញ្ជី

**ផ្នែកវិន័យ**

- ដោះស្រាយរាល់ពាក្យប្តឹងជំទាស់ពីក.ឆ.ភ
- រៀបចំនិតិវិធីដោះស្រាយបណ្តឹងនិងវិន័យ
- ផ្តល់ប្រឹក្សាយោបល់ពីបញ្ហាវិន័យដល់ក.ឆ.ភ

**ផ្នែកហិរញ្ញវត្ថុនិងសវនកម្ម**

- បង្កើតគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ
- បង្កើតផែនការអនុវត្តប្រចាំឆ្នាំនិងថវិកា
- ធ្វើសវនកម្មការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក.ឆ.ខ និង ក.ឆ.ភ

# <u>រចនាសម្ព័ន្ធក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ(ក.ឆ.ភ)</u>

**ប្រធាន**

- **ផ្នែកវិន័យ**
  - ទទួលពាក្យបណ្ដឹងនិងដោះស្រាយ
- **ផ្នែកបណ្ដុះបណ្ដាល**
  - អភិវឌ្ឍសមត្ថភាពរបស់សាលាបណ្ដុះបណ្ដាលឆ្មបក្នុងការវាយតម្លៃសមត្ថភាពឆ្មប
  - ផ្សព្វផ្សាយពីគោលនយោបាយនិងបទបញ្ញាផ្សេងៗដល់សមាជិក
- **ផ្នែកហិរញ្ញវត្ថុ**
  - រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាព និងផ្ញើជូន ក.ឆ.ជ

# <u>រចនាសម្ព័ន្ធក្រុមប្រឹក្សាគណៈឆ្មបរាជធានី-ខេត្ត</u>

**ប្រធាន**

- **ផ្នែកចុះបញ្ជីរ**
  - ចុះបញ្ជីរសមាជិកនិងប្រមូលថវិកា
  - ត្រួតពិនិត្យពាក្យសុំចូលសមាជិក
  - ទំនាក់ទំនងជាមួយឆ្មប
  - ផ្ញើពាក្យបណ្ដឹងទៅក.ឆ.ភ
- **ផ្នែកបណ្ដុះបណ្ដាល**
  - ផ្សព្វផ្សាយដល់សមាជិកអំពីបទបញ្ញានិងគោលនយោបាយស្តង់ដាររបស់គណៈឆ្មបកម្ពុជា
  - គាំទ្រនិរន្តភាពនៃដំណើរការកែលម្អរគុណភាពសេវាឆ្មប
- **ផ្នែកហិរញ្ញវត្ថុ**
  - រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាព និងផ្ញើជូន ក.ឆ.ភ និង ក.ឆ.ជ

## បញ្ជីឯកសារដែលពាក់ព័ន្ធ

១. ផែនការយុទ្ធសាស្រ្តរបស់គណៈឆ្មបកម្ពុជាឆ្នាំ២០១០-២០១៥
២. បទបញ្ជាផ្ទៃក្នុងរបស់គណៈឆ្មបកម្ពុជា ឆ្នាំ២០១២
៣.ស្តង់ដារសកលសម្រាប់បទបញ្ជាឆ្មបរបស់សហព័ន្ធឆ្មបអន្តរជាតិ(ICM) ឆ្នាំ២០១១
៤. ស្តង់ដារសកលសម្រាប់ការអប់រំឆ្មបរបស់ICM ឆ្នាំ២០១០
៥. សមត្ថភាពជំនាញសារវន្តនៃការអនុវត្តន៍ជាមូលដ្ឋានរបស់ឆ្មបរបស់ICM ឆ្នាំ២០១០
៦. ឧបករណ៍ពង្រឹងការងារឆ្មបរបស់អង្គការសុខភាពពិភពលោក(WHO) ឆ្នាំ២០០៣

## ព័ត៌មានបន្ថែម

**ការិយាល័យក្រុមប្រឹក្សាគណៈឆ្មបជាតិ**


**គណៈឆ្មបកម្ពុជា**

ក្រសួងសុខាភិបាល

អាគារលេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទដៃ: (៨៥៥) ១២ ៧៣៥ ២៥១/០១២ ៩៤០ ៥៥២

ទូរស័ព្ទលើតុ: (៨៥៥) ២៣ ៩៩០ ៣៨៣

ទូរសារ: (៨៥៥) ២៣ ៨៨៤ ៩០៩

អ៊ីម៉េល: info.cmccambodia@gmail.com

គេហទំព័រ: www.cmidwivesc.org

## ការិយាល័យក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ

| ល.រ | ភូមិភាគ | ទូរស័ព្ទដៃ |
|---|---|---|
| ១ | ទី១ (ភ្នំពេញ) | 077 286 886 |
| ២ | ទី២ (បាត់ដំបង) | 012 971 534 |
| ៣ | ទី៣ (កំពត) | 012 995 298 |
| ៤ | ទី៤ (ស្ទឹងត្រែង) | 012 664 797 |
| ៥ | ទី៥ (កំពង់ចាម) | 011 662 665 |

## ការិយាល័យក្រុមប្រឹក្សាគណៈឆ្មបរាជធានីខេត្ត

| ល.រ | សាខារាជធានី-ខេត្ត | ទូរស័ព្ទដៃ | ល.រ | សាខារាជធានី-ខេត្ត | ទូរស័ព្ទដៃ |
|---|---|---|---|---|---|
| ១ | មជ្ឈមណ្ឌលជាតិគាំពារមាតា-ទារក | 099 723 672<br>016 937 220 | ៦ | ខេត្តតាកែវ | 017 391 933<br>012 303 074 |
| ២ | មន្ទីរពេទ្យកាលម៉ែត | 012 952 936<br>012 765 224 | ៧ | ខេត្តកោះកុង | 012 624 354<br>097 789 8227 |
| ៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | 012 757 670<br>097 701 8286 | ៨ | ខេត្តព្រះសីហនុ | 016 243 467<br>016 690 485 |
| ៤ | រាជធានីភ្នំពេញ | 012 413 861<br>095 766 976 | ៩ | ខេត្តកែប | 012 599 277<br>017 918 178 |
| ៥ | ខេត្តកណ្តាល | 012 459 429<br>077 366 838 | ១០ | ខេត្តស្ទឹងត្រែង | 011 208 442<br>012 659 986 |

| | | | | | |
|---|---|---|---|---|---|
| ១១ | ខេត្តកំពង់ស្ពឺ | 012 483 818<br>097 740 0483 | ២០ | ខេត្តរតនៈគីរី | 011 673 987<br>012 423 752 |
| ១២ | ខេត្តកំពង់ឆ្នាំង | 099 210 226<br>078767766 | ២១ | ខេត្តមណ្ឌលគីរី | 012 316 027<br>097 669 6300 |
| ១៣ | ខេត្តបាត់ដំបង | 012 836 825<br>012 836 723 | ២២ | ខេត្តក្រចេះ | 011 903 138<br>011 258 579 |
| ១៤ | ខេត្តពោធិ៍សាត់ | 012 990 632<br>092 933 044 | ២៣ | ខេត្តព្រះវិហារ | 012 371 618<br>097 982 0896 |
| ១៥ | ខេត្តបន្ទាយមានជ័យ | 012 956 994<br>012 961 491 | ២៤ | ខេត្តកំពង់ចាម | 012 553 562<br>011 852 872 |
| ១៦ | ខេត្តសៀមរាប | 012 630 040<br>012 967 911 | ២៥ | ខេត្តកំពង់ធំ | 012 234 263<br>012 248 422 |
| ១៧ | ខេត្តឧត្តមានជ័យ | 011 210 121<br>011 628 527 | ២៦ | ខេត្តព្រៃវែង | 011 234 960<br>092 807 087 |
| ១៨ | ខេត្តប៉ៃលិន | 078 506 469<br>012 240 053 | ២៧ | ខេត្តស្វាយរៀង | 012 428 018<br>016 327 671 |
| ១៩ | ខេត្តកំពត | 012 330 195<br>012 995 288 | | | |

# **គណៈឆ្មបកម្ពុជា**


អស័យដ្ឋាន: ក្រសួងសុខាភិបាល

អាគារលេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទដៃ: (៨៥៥) ១២ ៧៣៥ ២៥១/០១២ ៩៤០ ៥៥២

ទូរស័ព្ទលើតុ:(៨៥៥) ២៣ ៩៩០ ៣៨៣

ទូរសារ: (៨៥៥) ២៣ ៨៨៤ ៩០៩

អ៊ីម៉ែល: info.cmccambodia@gmail.com

គេហទំព័រ: www.cmidwivesc.org



រក្សាសិទ្ធិដោយគណៈឆ្មបកម្ពុជា



បោះពុម្ពលើកទី១ដោយគណៈឆ្មបកម្ពុជា ភ្នំពេញ ឆ្នាំ២០១៣

ឧបត្ថម្ភថវិកាដោយ HSSP2/UNFPA


*ការពារសាធារណជនតាមរយៈបទដ្ឋានវិជ្ជាជីវៈឆ្មប*